# យុត្តិធម៌និងការផ្សះផ្សាសម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហម ?

## ការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណើរការយុត្តិធម៌អន្តរកាលនៅកម្ពុជា

**របាយការណ៍សង្ខេប**

ខែវិច្ឆិកា ឆ្នាំ ២០១៨

ទីម៉ូធី វីលៀមន៍ (Timothy WILLIAMS)    ជូលី ប៊ែរណាត (Julie BERNATH)    តាន់ បូរ៉ាវីន    គុំ សុម៉ាលី

ការស្រាវជ្រាវនេះ សំដៅស្វែងយល់ពីទស្សនៈរបស់ជនរងគ្រោះលើភាពយុត្តិធម៌និងការផ្សះផ្សានៅកម្ពុជា និងឥទ្ធិពលនៃការរួមបញ្ចូលជនរងគ្រោះ ក្នុងដំណើរការយុត្តិធម៌អន្តរកាល ។ កិច្ចការនេះទទួលបានការចាប់អារម្មណ៍ជាពិសេស ដោយហេតុថាមានការចំណាយធនធាននិងបានផ្តល់ក្តីសង្ឃឹមជាច្រើន ដើម្បីជួយឱ្យជនរងគ្រោះបានចូលរួមនៅក្នុងដំណើរការយុត្តិធម៌អន្តរកាលនៅកម្ពុជា ទាំងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) និងនៅក្នុងគម្រោងនានារបស់អង្គការសង្គមស៊ីវិល។ ទិន្នន័យរបស់យើងបានប្រមូលចេញពីការស្ទង់មតិ និងកិច្ចសម្ភាសន៍លម្អិតជាមួយជនរងគ្រោះនៃរបបខ្មែរក្រហម ដែលបានចូលរួមតាមច្រើនទម្រង់។ ទិន្នន័យនេះត្រូវបានប្រមូលនៅចន្លោះខែមករា និងខែមិថុនា ឆ្នាំ ២០១៨ ។ បន្ថែមពីលើការស្ទង់មតិនិងកិច្ចសម្ភាសន៍លម្អិតដូចបានរៀបរាប់ យើងក៏បានធ្វើកិច្ចសម្ភាសន៍ជាមួយអ្នកជំនាញយុត្តិធម៌អន្តរកាលនៅកម្ពុជាចំនួន ២១ រូប ។

ការស្ទង់មតិជាមួយជនរងគ្រោះនៃរបបខ្មែរក្រហមចំនួន **៤៣៩** នាក់




- ដើមបណ្តឹងរដ្ឋប្បវេណី
- អ្នកប្តឹងធម្មតា
- អ្នកចូលរួមក្នុងកម្មវិធីអង្គការក្រៅរដ្ឋាភិបាល
- អ្នកមិនបានចូលរួមសោះ *




កិច្ចសម្ភាសន៍លម្អិតជាមួយនឹងជនរងគ្រោះចំនួន **៦៥** នាក់

* អ្នកផ្តល់ចម្លើយដែលមិនបានចូលរួមសោះ ជាដើមបណ្តឹងរដ្ឋប្បវេណី ឬ អ្នកប្តឹងធម្មតានៅ អ.វ.ត.ក ឬ ក្នុងគម្រោងអង្គការក្រៅរដ្ឋាភិបាល ស្តីពី អ.វ.ត.ក / របបខ្មែរក្រហមណាមួយ។

## យុត្តិធម៌

អ្នកចូលរួមក្នុងការស្ទង់មតិ បានផ្តល់និយមន័យពាក្យយុត្តិធម៌ច្រើនបែបយ៉ាង ដោយផ្តោតជាសំខាន់លើ "ស្គាល់អ្នកខុស និងអ្នកត្រូវ" "ការស្វែងរកការពិត" និងគោលគំនិតនៃភាពយុត្តិធម៌ ភាពស្មោះត្រង់ តម្លាភាព និងអព្យាក្រឹត្យភាព។ កិច្ចសម្ភាសន៍លម្អិតបានបង្ហាញពីគោលគំនិតយុត្តិធម៌បែបទណ្ឌកម្ម ឬបែបកម្មពៀរ ហើយនិងបែបយុត្តិធម៌សង្គម ដែលកំណត់ភាពយុត្តិធម៌ក្នុងក្របខណ្ឌការគាំទ្រសង្គមសេដ្ឋកិច្ច។ ជំនឿព្រះពុទ្ធសាសនា មិនបានធ្វើឱ្យប៉ះពាល់ដល់ទស្សនៈទាំងនេះទេ ប៉ុន្តែបានបំពេញបន្ថែម ដោយអនុញ្ញាតឱ្យអ្នកចូលរួមក្នុងកិច្ចសម្ភាសន៍ ស្វែងយល់ពីយុត្តិធម៌ព្រហ្មទណ្ឌទាំងផ្នែកគតិយុត្តិ និងរចនាសម្ព័ន្ធស្ថាប័ននៅ អ.វ.ត.ក តាមរយៈទស្សនទានព្រះពុទ្ធសាសនារបស់ពួកគេ។

ដូចគ្នានឹងការសិក្សាមុនៗ ការស្ទង់មតិផ្តល់ការវាយតម្លៃជាវិជ្ជមានថាជនរងគ្រោះនៃរបបខ្មែរក្រហមទទួលបានយុត្តិធម៌។ កិច្ចសម្ភាសន៍លម្អិត ផ្ទុយទៅវិញបានបង្ហាញថាបញ្ហាសំណងជាលក្ខខណ្ឌកំណត់យ៉ាងសំខាន់ដែលធ្វើឱ្យដំណើរការស្វែងរកយុត្តិធម៌នៅមានកម្រិត។ បញ្ហាផ្សេងទៀតដែលបានលើកឡើង រួមមានការជ្រៀតជ្រែកផ្នែកនយោបាយនៅតុលាការ ការមិនទទួលស្គាល់កំហុសរបស់ជនជាប់ចោទ និងការអូសបន្លាយពេលវេលាក្នុងដំណើរការជំនុំជម្រះ។ ការចូលរួមចំណែករបស់អ.វ.ត.ក ក្នុងដំណើរការស្វែងរកយុត្តិធម៌ត្រូវបានវាយតម្លៃជាវិជ្ជមាន ប៉ុន្តែអង្គការក្រៅរដ្ឋាភិបាលក៏ត្រូវបានគេចាត់ទុកថាជាតួអង្គសំខាន់ផងដែរ។

តើអ្នកជឿថាជនរងគ្រោះក្នុងរបបខ្មែរក្រហមទទួលបានយុត្តិធម៌ដែរឬទេ?






តើអ្នកគិតថា អ.វ.ត.ក បានផ្តល់យុត្តិធម៌ដល់ជនរងគ្រោះនៃរបបខ្មែរក្រហមនិងគ្រួសាររបស់ពួកគាត់ដែរឬទេ?

តើភាពជាដើមបណ្តឹងរដ្ឋប្បវេណី/អ្នកប្តឹងធម្មតា/អ្នកចូលរួមក្នុងគម្រោងអង្គការក្រៅរដ្ឋាភិបាល បានធ្វើឲ្យ ពូ/មីង មានអារម្មណ៍ថាទទួលបានយុត្តិធម៌ដែរឬទេ?




## ការផ្សះផ្សា

នៅពេលសួរថា តើការផ្សះផ្សាមានន័យយ៉ាងណាចំពោះពួកគាត់ ស្ទើរតែពាក់កណ្តាលនៃអ្នកចូលរួមស្ទង់មតិ សំដៅទៅលើគំនិតនៃសាមគ្គីភាពនិងការរួមរស់ជាមួយគ្នា ខណៈដែលជាង ១/៥ ទៀត យល់ឃើញថាការផ្សះផ្សា ជាភាពគ្មានអំពើហិង្សានិងជម្លោះ។ ក្នុងកិច្ចសម្ភាសន៍លម្អិត ក៏បានទាញភ្ជាប់ទស្សនៈរបស់ព្រះពុទ្ធសាសនាដែលសំដៅលើការអភ័យទោស និងការមិនចងគំនុំ។ ក្នុងន័យនេះ អ្នកផ្តល់ចម្លើយបានបង្ហាញការបកស្រាយជា "វិជ្ជមាន" ចំពោះការផ្សះផ្សាក្នុងន័យសាមគ្គីភាពនិងភាពសុខដុម ជាជាងភាពគ្មានជម្លោះ និងអំពើហិង្សាដែលមានន័យ "អវិជ្ជមាន" ។ ការផ្សះផ្សាត្រូវបានយល់ឃើញជាទូទៅថាជាលទ្ធផល ដែលសម្រេចបានដោយមានអន្តរាគមន៍ពីខាងក្រៅជាជាងដំណើរការរវាងតួអង្គនានា។ ការរួមចំណែករបស់ អ.វ.ត.ក និងគម្រោងនានារបស់អង្គការក្រៅរដ្ឋាភិបាលក្នុងការផ្សះផ្សាត្រូវបានវាយតម្លៃជាវិជ្ជមាន ប៉ុន្តែរដ្ឋាភិបាលនិងសាសនាក៏ត្រូវបានគេចាត់ទុកថាជាតួអង្គគន្លឹះ ក្នុងការផ្សះផ្សាដោយបានសង្កត់ធ្ងន់លើការរួមចំណែក នៃទស្សនៈព្រះពុទ្ធសាសនាលើការបំពេញបន្ថែមលើវិធានការយុត្តិធម៌អន្តរកាលទូទៅ។

តើអ្នកគិតថា អ.វ.ត.ក / គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលបានរួមចំណែកដល់ការផ្សះផ្សានៅកម្ពុជាដែរឬទេ?







គម្រោងអង្គការក្រៅរដ្ឋាភិបាល

កម្រិតនៃការផ្សះផ្សានៅកម្ពុជា នៅមានលក្ខណៈតិចតួចនៅតាមសហគមន៍មូលដ្ឋាន ដែលអាចបណ្តាលមកពីគោលនយោបាយក្រោយរបបខ្មែរក្រហម ដែលបានបង្វែរការដាក់បន្ទុកទាំងអស់ពីអតីតខ្មែរក្រហមកម្មាភិបាលថ្នាក់ក្រោម ទៅលើមេដឹកនាំខ្មែរក្រហម និងអង្គការបដិវត្តន៍។

**៧៥.៦%**

នៃជនរងគ្រោះនៅតែមានអារម្មណ៍ស្អប់ចំពោះអតីតខ្មែរក្រហមដែលទទួលខុសត្រូវលើអំពើហិង្សា

អតីតខ្មែរក្រហមថ្នាក់ក្រោមគ្រាន់តែអនុវត្តតាមបញ្ជា ហើយក៏ជាជនរងគ្រោះនៃ "អង្គការ" ផងដែរ



## អ.វ.ត.ក

ទិន្នន័យដែលយើងមានបង្ហាញថាការយល់ដឹងទូទៅអំពី អ.វ.ត.ក និងសំណុំរឿង ០០១ និង ០០២ គឺនៅមានកម្រិតទាប។ បើពិនិត្យមើលលើស្ថិតិ យើងឃើញថាវាមានការពាក់ព័ន្ធយ៉ាងខ្លាំងរវាងកម្រិតនៃការចូលរួមនៅ អ.វ.ត.ក និងកម្រិតនៃការយល់ដឹងរបស់បុគ្គលម្នាក់ៗអំពីអ.វ.ត.ក មានន័យថាបើគាត់បានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីកាន់តែច្រើននោះចំណេះដឹងរបស់ពួកគាត់កាន់តែប្រសើរឡើង។ បន្ថែមពីនេះទៀត ការយល់ដឹងរបស់បុរសមានកម្រិតខ្ពស់ជាងស្រ្តី ដែលឆ្លុះបញ្ចាំងពីឱកាសទទួលបានការអប់រំជាទូទៅក្នុងសង្គមបិតាធិបតេយ្យនៅកម្ពុជា ប៉ុន្តែស្ថិតិសម្រាប់ករណីដើមបណ្ដឹងរដ្ឋប្បវេណី មិនបានបង្ហាញដូចគ្នានោះទេ។

**៧៦.៣%**
ជឿជាក់ថា
អ.វ.ត.ក ឯករាជ្យ

ឯករាជ្យភាព និងការជឿទុកចិត្តលើអ.វ.ត.ក ត្រូវបានមើលឃើញ ថាមានលក្ខណៈជាវិជ្ជមាន។ នៅក្នុងការស្ទង់មតិបុគ្គលិកកម្ពុជា ដែលបម្រើការងារនៅអ.វ.ត.ក ទទួលបានការជឿទុកចិត្តច្រើនបំផុត ខណៈដែលក្នុងកិច្ចសម្ភាសន៍លម្អិត ជនរងគ្រោះបានបង្ហាញការមិនជឿទុកចិត្តលើបុគ្គលិកជាតិ ហើយមានទំនុកចិត្តខ្ពស់លើបុគ្គលិកអន្តរជាតិវិញ។ ពួកគាត់ បានបង្ហាញទស្សនៈវិជ្ជមាន ដោយបង្ហាញពីចេតនាចង់ឱ្យ អ.វ.ត.ក បន្តការងារ ហើយ ៨០.២% នៃអ្នកចូលរួមស្ទង់មតិចង់ឱ្យមានការកាត់ក្ដីលើសំណុំរឿង ០០៣ និង ០០៤ ។

**៨០.២%**
ទុកចិត្តលើ
អ.វ.ត.ក

ឱកាសក្នុងការចូលរួម និងព័ត៌មានស្ដីពីដំណើរការនីតិវិធីរបស់អ.វ.ត.ក ដែលអាចជាការគំរាមកំហែងដល់សមិទ្ធផលមុនៗនិងអាចឈានទៅរកការថមថយនៃដំណើរការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជាចំណាប់អារម្មណ៍របស់គាត់លើអ.វ.ត.ក។ អ្នកប្ដឹងធម្មតាជាទូទៅមានការពេញចិត្តភាគច្រើន។ ១/៥នៃអ្នកប្ដឹងធម្មតាមានឱកាសចូលរួមស្ដាប់សវនាការ ឬមកទស្សនកិច្ចនៅអ.វ.ត.ក ដែលជាការសបញ្ជាក់ពីភាពខុសគ្នាយ៉ាងច្រើន រវាងឱកាសនៃការចូលរួមរបស់អ្នកប្ដឹងធម្មតានិងដើមបណ្ដឹងរដ្ឋប្បវេណី។







## ការចូលរួម

កត្តាជម្រុញទឹកចិត្តដ៏សំខាន់សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកប្ដឹងធម្មតាក្នុងការចូលរួមនៅអ.វ.ត.ក គឺដើម្បីទទួលបានយុត្តិធម៌ ការទទួលស្គាល់នូវការឈឺចាប់ ការប្រាប់ពីរឿងរ៉ាវរបស់ពួកគាត់ ក៏ដូចជាដើម្បីស្វែងរកការពិត។ នៅក្នុងការស្ទង់មតិនេះផងដែរ ប្រហែល ១/៣នៃដើមបណ្ដឹងរដ្ឋប្បវេណី និង១/៦នៃអ្នកប្ដឹងធម្មតា មានការភ័យខ្លាចនៅពេលដាក់ពាក្យបណ្ដឹង ជាពិសេសបារម្ភពីការសងសឹកឬសម្ពាធពីជនជាប់ចោទនិងក្រុមគ្រួសាររបស់ពួកគេ ។

ដើមបណ្ដឹងរដ្ឋប្បវេណីភាគច្រើន ពេញចិត្តនឹងការចូលរួមរបស់ពួកគាត់។ ការជួបជុំជាមួយដើមបណ្ដឹងផ្សេងទៀត ការចូលរួមក្នុងវេទិការបស់ដើមបណ្ដឹងនិងការធ្វើទស្សនកិច្ចនៅអ.វ.ត.ក សុទ្ធតែជាបទពិសោធដ៏សំខាន់បំផុតសម្រាប់ពួកគាត់។ ទោះជាយ៉ាងណាក៏ដោយ ពួកគាត់បានលើកឡើងពីការថយចុះគួរឱ្យកត់សម្គាល់នៃ

៨០% នៃដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានផ្ដល់សក្ខីកម្មនៅអ.វ.ត.ក បានចាត់ទុកវាជាបទពិសោធន៍វិជ្ជមានមួយ ដែលអាចឱ្យគាត់និយាយរឿងរ៉ាវជាសាធារណៈ ឬប្រឈមមុខនឹងជនជាប់ចោទ។ ក្នុងនោះក៏មាន ការលើកឡើងពីភាពអវិជ្ជមានផងដែរ ដូចជាការណ៍ដែលមិនអាចចែករំលែករឿងរ៉ាវរបស់ខ្លួនទាំងស្រុង ភាពភ័យខ្លាចក្នុងការនិយាយនៅមុខមហាជន និងចែករំលែករឿងរ៉ាវរបស់ខ្លួនជាសាធារណៈ មុននឹងរៀបរាប់ប្រាប់សាច់ញាតិរបស់ខ្លួន។

អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនដែលត្រូវបានច្រានចោល ហើយមិនបានដឹងពីស្ថានភាពនេះបានសម្ដែងអារម្មណ៍ខកចិត្ត និងអស់សង្ឃឹមចំពោះការបដិសេធនោះ ហើយថែមទាំងមានមន្ទិលចំពោះភាពជាជនរងគ្រោះរបស់ខ្លួនទៀតផង។

ច្រើនជាងពាក់កណ្ដាលនៃអ្នកចូលរួមនៅក្នុងគម្រោងរបស់អង្គការក្រៅរដ្ឋាភិបាល ដែលបានជ្រើសរើសក្នុងការស្ទង់មតិរបស់យើង

មិនចាំអំពីការចូលរួមរបស់ពួកគាត់ទេ ខណៈអ្នកដែលនៅចងចាំបានបញ្ចេញការពេញចិត្តជាខ្លាំងចំពោះបទពិសោធន៍ទាំងនោះ។

## ការមិនចូលរួម

ការមិនចូលរួមនៅអ.វ.ត.ក ភាគច្រើនត្រូវបានធ្វើឡើងតាមគោលការណ៍មិនស្ម័គ្រចិត្ត ហើយបុព្វហេតុសំខាន់គឺកង្វះខាតបុរេលក្ខខណ្ឌចាំបាច់ សម្រាប់ការចូលរួមប្រកបដោយអត្ថន័យនៅដំណាក់កាលដំបូងនៃដំណើរការយុត្តិធម៌អន្តរកាល ដែលរួមមានកង្វះខាតព័ត៌មានអំពី អ.វ.ត.ក ភាពមិនប្រាកដថាអាចចូលរួមបាន ភាពភ័យខ្លាច អសមត្ថភាពរបស់បុគ្គល ជាពិសេសពេលវេលាមិនគ្រប់គ្រាន់ឬអាយុកាលចំណាស់របស់ជនរងគ្រោះ។ ទឡ្ហីករណ៍លើការស្ម័គ្រចិត្តមិនចូលរួមក៏ត្រូវបានរកឃើញផងដែរនៅក្នុងការស្ទង់មតិនេះ ដោយពួកគាត់ឆ្លើយថាការមិនចូលរួមគឺជាជម្រើសមួយដែលសមស្រប ដោយសារៈ ១) ការចំណាយច្រើនជាងប្រយោជន៍ដែលនឹងទទួលបាន ២) ការមិនពេញចិត្តនឹងអ.វ.ត.ក ឬ ៣) ការមិនចាប់អារម្មណ៍លើ អ.វ.ត.ក។

## ការពង្រឹងសមត្ថភាព

ការចូលរួមបានជួយដល់ដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើន ទទួលយកប្រសើរជាងមុន ពីការបាត់បង់មនុស្សជាទីស្រលាញ់របស់ខ្លួន ជួយឱ្យស្មារតីរបស់ពួកគាត់កាន់តែរឹងមាំ ផ្ដល់ក្ដីសង្ឃឹមនាពេលអនាគត និងផ្ដល់ទំនុកចិត្តឱ្យពួកគាត់រៀបរាប់អំពីរឿងរ៉ាវផ្ទាល់ខ្លួន។ លើសពីនេះ ការចូលរួមបានរួមចំណែកបង្កើនចំណេះដឹង ដែលផ្ដល់ឱកាសកាន់តែច្រើនឱ្យពួកគាត់បំពេញតួនាទីយ៉ាងសកម្មនៅក្នុងសហគមន៍របស់គាត់ ជួយឱ្យដើមបណ្ដឹងរដ្ឋប្បវេណីពិចារណាច្បាស់លាស់អំពីគំនិតនិងការទាមទាររបស់ពួកគាត់។ បុគ្គលខ្លះត្រូវបានពង្រឹងសមត្ថភាពតាមវិធីសាស្ត្រចម្រូងចម្រាស់មួយចំនួន ក្នុងកិច្ចដំណើរការនៃប្រព័ន្ធយុត្តិធម៌អន្តរកាល តាមរយៈការធ្វើពហិការ បាតុកម្មឬការចុះហត្ថលេខាលើញត្តិ នៅពេលដែលមានការប៉ះពាល់ដល់ផលប្រយោជន៍របស់ពួកគាត់។ ទោះជាយ៉ាងណាក៏ដោយ ការពង្រឹងសមត្ថភាពត្រូវបានកាត់បន្ថយឬនៅមានកម្រិត អាស្រ័យលើកម្មវិធីដែលបានរៀបចំឡើង ពោលគឺមានលក្ខណៈអកម្មច្រើនជាងការចូលរួមដោយសកម្ម។ អ្នកចូលរួមខ្លះក្នុងការស្រាវជ្រាវរបស់យើងបានលើកឡើងថាពួកគេត្រូវបានគេស្ដីបន្ទោសនៅពេលដែលពួកគាត់និយាយចំៗឬរិះគន់ខ្លាំងពេក។ បន្ថែមពីលើនេះទៀត ពួកគាត់យល់ឃើញថាការចូលរួមក្នុងកម្មវិធីទាំងនេះ មិនមានភាពស្មើគ្នាសម្រាប់ជនរងគ្រោះទាំងអស់នោះទេ ពោលគឺមិនបានផ្ដល់ឱកាសដល់ជនរងគ្រោះផ្សេងទៀត ដែលមិនស្ថិតនៅក្នុងបណ្ដាញបក្សពួករបស់គេឡើយ។

## សំណង

វាជារឿងដែលគួរឱ្យភ្ញាក់ផ្អើល អ្នកផ្ដល់ចម្លើយចំនួន ៨១.៤% (រួមទាំងដើមបណ្ដឹងរដ្ឋប្បវេណីភាគច្រើនផងដែរ) មិនបានដឹងអំពីគម្រោងសំណងណាមួយ និងមានចំណេះដឹងតិចតួចអំពីអ្វីដែលចាត់ទុកជាសំណង។ ២២.២% នៃអ្នកចូលរួមក្នុងការស្ទង់មតិនេះ ជឿជាក់ថាសំណងហិរញ្ញវត្ថុជាលក្ខណៈបុគ្គល សមស្របបំផុតសំរាប់ជនរងគ្រោះនាពេលសព្វថ្ងៃនេះ។ ៩៣.៩% យល់ស្របថាវាចាំបាច់ក្នុងការផ្ដល់ *សំណងនិមិត្តរូប* ដូចជាទីតាំងគោរពវិញ្ញាណក្ខន្ធ សេវាសុខភាព ការអប់រំឬហេដ្ឋារចនាសម្ព័ន្ធ។ ការទាមទារសំណងហិរញ្ញវត្ថុជាលក្ខណៈបុគ្គល ត្រូវបានលើកឡើងជារឿយៗ នៅក្នុងកិច្ចសម្ភាសន៍លម្អិត ជាពិសេសដើម្បីរៀបចំពិធីបុណ្យសាសនាសម្រាប់មនុស្សជាទីស្រឡាញ់ ដែលបានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម និងសំណងសមូហភាព ដូចជា ការសាងសង់ចេតិយ ឬទីតាំងគោរពវិញ្ញាណក្ខន្ធជាដើម ការផ្ដល់សេវាសង្គម (ការថែទាំសុខភាព និងការអប់រំ) ឬការបង្កើតមូលនិធិសម្រាប់ជនរងគ្រោះ។ នៅពេលសួរអំពីពេលអនាគត ៦៤.៧% នៃអ្នកចូលរួមរំពឹងចង់បានសំណងហិរញ្ញវត្ថុ (ជាលក្ខណៈបុគ្គល) និង ៦១.៣% បានលើកឡើងពីការបង្កើតគណៈកម្មការស្វែងរកការពិត។ អ្នកផ្សេងទៀតបានរៀបរាប់ពីចំណុចផ្សេងទៀត ដូចជាសន្តិភាព និងការបង្ការកុំឱ្យកើតមានឡើងវិញនូវរបបខ្មែរក្រហម យុត្តិធម៌និងការកាត់ទោសបន្ថែមទៀត។

**៦០.៦%**
នៃអ្នកផ្ដល់ចម្លើយបានលើកឡើងថាសំណងគួរត្រូវបានផ្ដល់ដល់សហគមន៍ទាំងមូល ខណៈដែល
**៣៨.៨%**
គិតចង់បានសំណងជាលក្ខណៈបុគ្គល

ការស្រាវជ្រាវនេះ ក៏ដូចជាការបោះពុម្ពផ្សាយរបាយការណ៍សង្ខេបទទួលបានការគាំទ្រជាថវិកាពីក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍អាល្លឺម៉ង់ (BMZ) ។

សម្រាប់ព័ត៌មានបន្ថែម សូមមើលរបាយការណ៍របស់យើងតាមៈ

http://www.uni-marburg.de/cambodia-victimhood